ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តមណ្ឌលគិរី
សំណុំរឿងព្រហ្មទណ្ឌលេខ ៣២៧
ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២០
សាលក្រមព្រហ្មទណ្ឌ
លេខ ១៣២ /២១ "ឃ"
ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តមណ្ឌលគិរី

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នាថ្ងៃព្រហស្បតិ៍ ១កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ដោយមានសមាសភាព៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូង ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ចៅក្រមសាលាដំបូង ជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូង ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តមណ្ឌលគិរី

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៣២៧ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២០ ដែលប្តឹងមកតុលាការតាមដីកាដំណោះស្រាយលេខ ២៥៩៦/២០ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ មានជនជាប់ចោទ៖

ឈ្មោះ [redacted] សារម៉េន ភេទប្រុស កើតថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៨៧ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតភូ[redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិអន្ទ្រេះ ឃុំអរប្ងនលើ ស្រុកកោះញែក ខេត្តមណ្ឌលគិរី ឪពុកឈ្មោះ [redacted] ម៉ី (ស្លាប់) ម្តាយឈ្មោះ [redacted] ផល្លី (រស់) ប្រពន្ធឈ្មោះ [redacted] សោភ័ណ្ឌ មានចំនួន ០២នាក់ ទោសពីមុន គ្មាន ជាតិជន កម្រិតវប្បធម៌ "រៀនថ្នាក់ទី៣"។

ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ១៤៥ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២០។

ជាប់ចោទពីបទ **កាប់គាស់រុករានដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅចំណុចអូរអន្ទ្រាច់ ស្ថិតនៅភូមិអរប្ងន ឃុំអរប្ងនលើ ស្រុកកោះញែក ខេត្តមណ្ឌលគីរី កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌចែងឲ្យផ្តន្ទាទោសតាមមាត្រា៦២ ចំណុច១ និងមាត្រា៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៥៤២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០។
- បានឃើញ ដីកាដំណោះស្រាយលេខ ២៥៩៦/២០ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០។



Scanned with CamScanner

- បានឃើញ ដីកាសម្រេចចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៤០២ រប/២០ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០។

- បានឃើញ ដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ ៤៨៨/២០ ចុះថ្ងៃ២៦ ខែឧសភា ឆ្នាំ២០២១។

**អង្គហេតុដែលបណ្ដឹងមកតុលាការ[១]**

កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង១០ និង៣០នាទី ក្រុមការងារផែនជម្រកសត្វព្រៃស្រែពក នៃមន្ទីរបរិស្ថានខេត្តមណ្ឌលគិរី បានចុះប្រតិបត្តិការល្បាតទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ បានចាប់ឃាត់ខ្លួនឈ្មោះ [redacted] សាម៉ែន ដែលបានកាប់រុករានដីព្រៃយកធ្វើជាកម្មសិទ្ធិ ត្រង់និយាមការលេខ ៧២៩៤៨៦-១៤៣៨៨០០ នៅចំណុចអូរអន្ត្រាច់ ស្ថិតនៅភូមិអរបួន ឃុំអរបួនលើ ស្រុកកោះញែក ខេត្តមណ្ឌលគិរី ដែលដីព្រៃហាមឃាត់នេះ គឺឈ្មោះ [redacted] សោភ័ណ្ឌ ដែលជាប្រពន្ធរបស់ឈ្មោះ [redacted] សាម៉ែន បានមកធ្វើកិច្ចសន្យាជាមួយសមត្ថកិច្ចបរិស្ថានម្តងរួចហើយ កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០។

**នារពេលសវនាការ**

- ជនជាប់ចោទឈ្មោះ [redacted] **សាម៉ែន** ភេទប្រុស អាយុ៣១ឆ្នាំ បានឆ្លើយថា៖ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ ខ្លួនបានយកដើមចេកទៅដាំមានចំនួន៥០ដើមនៅចំណុចអន្ត្រាច់ ស្ថិតនៅភូមិអរបួន ឃុំអរបួនលើ ស្រុកកោះញែក ខេត្តមណ្ឌលគិរី ដែលជាដីហាមឃាត់របស់បរិស្ថាន ដោយមានបង្គោលហាមឃាត់ផងដែរ ដោយខ្លួនគិតថា នៅពេលដែលគណៈកម្មការថ្នាក់ជាតិចុះមក គឺអាចធ្វើការឈ្ងៀលដីព្រៃឱ្យខ្លួន។ ដីព្រៃនោះខ្លួនបានធ្វើផ្ទះស្នាក់នៅទីនោះផងដែរ។ នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង១០ព្រឹក ខ្លួនបានឃើញមន្ត្រី បរិស្ថានមកដកដើមចេកដែលខ្លួនបានដាំនោះចេញ។ ខ្លួនសួរថា "ហេតុអ្វីបានដកដើមចេក ក្នុងដីរបស់ខ្ញុំអញ្ចឹង?" ពេលនោះមន្ត្រីបរិស្ថានសួរខ្លួនថា "ដីមានប្លង់បញ្ជាក់ថាជាដីរបស់ខ្លួនអត់?" ខ្លួនក៏យកចុងសន្លឹកដែលនិស្សិតបានឱ្យខ្លួនប្រគល់ឱ្យគាត់"។ ពេលមន្ត្រីបរិស្ថានមើលរួចគាត់ថា "អ្នកមិនមានប្លង់ទេ គ្រាន់តែជាចុងសន្លឹកតែប៉ុណ្ណោះ" ហើយគាត់ក៏បានចាប់ឃាត់ខ្លួនតែម្តង។ ដីព្រៃដែលសមត្ថកិច្ចបានហាមឃាត់នេះ គឺប្រពន្ធខ្លួនធ្លាប់បានធ្វើកិច្ចសន្យាម្តងរួចមកហើយ។

- អំណានកំណត់ហេតុបទល្មើស ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២០ របស់ផែនជម្រកសត្វព្រៃស្រែពក នៃមន្ទីរបរិស្ថានខេត្តមណ្ឌលគិរី។

- **តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំដូចតទៅ៖** ក្រោយពីបានពិភាក្សាដេញដោលរួច តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទពិតជាបានធ្វើការកាប់រានព្រៃដាំដើមចេញ ក្នុងគោលបំណងយកជាកម្មសិទ្ធិប្រាកដមែន ហើយកន្លងមកប្រពន្ធរបស់ជនជាប់ចោទធ្លាប់បានធ្វើកិច្ចសន្យាជាមួយមន្ត្រីបរិស្ថានម្តងរួចមកហើយ ដូច្នេះតំណាងអយ្យការ ប្តឹងសុំតម្កល់ការចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរលេខ ៥៤២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ ដដែល។

- **មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានស្នើសុំដូចតទៅ៖** ក្រោយពីបានស្តាប់កិច្ចពិភាក្សាដេញដោលរួចមក ឃើញថា ការចូលកាន់កាប់ដីរបស់កូនក្តីខ្លួន នៅចំណុចអន្ត្រាច់ ស្ថិតនៅភូមិអរបួន ឃុំអរបួនលើ ស្រុកកោះញែក ខេត្តមណ្ឌលគិរី ដោយសារពុំបានដឹងថា ការកាន់កាប់ដីនោះខុសច្បាប់។ ម្យ៉ាង

---

[១] មាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ



Scanned with CamScanner

ទៀតកូនក្តីខ្លួនបានរៀនសូត្រតិចតួច មានការយល់ដឹងតិច ហើយស្ថានភាពគ្រួសារក្រីក្រ និងប្រពន្ធមានជម្ងឺក្នុងបន្ទុក ហើយបច្ចុប្បន្នប្រពន្ធរកប្រាក់ចំណូលតែម្នាក់ឯង ព្រមទាំងជាពលរដ្ឋស្លូតត្រង់ ពុំធ្លាប់ប្រព្រឹត្តបទល្មើសពីមុនមក ដូច្នេះស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ ផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន ដើម្បីចូលរួមរស់ក្នុងសង្គម និងជួយគ្រួសារដែលខ្វះខាត។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

- ជនជាប់ចោទនិយាយសម្តីចុងក្រោយ៖ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះបន្ធូរបន្ថយទោសដល់ខ្លួនផង។
- ផ្អែកតាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានស្នើសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។
- ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ។
- ក្រោយពីបានពិនិត្យឯកសារភស្តុតាងក្នុងសំណុំរឿងចប់សព្វគ្រប់។

## សំអាងហេតុ

១. តាមកំណត់ហេតុនៃបទល្មើស របស់ដែនជម្រកសត្វព្រៃស្រែពក និងចម្លើយសារភាពរបស់ជនជាប់ចោទ មានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងនានាក្នុងសំណុំរឿង បញ្ជាក់បានថា៖ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ នៅចំណុចអូរអន្ទ្រាច់ ស្ថិតនៅភូមិអរបួន ឃុំអរបួនលើ ស្រុកកោះញែក ខេត្តមណ្ឌលគិរី ពិតជាមានអង្គហេតុនៃបទល្មើស កាប់គាស់រុនរានដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ ប្រាកដមែន ដោយកម្លាំងសមត្ថកិច្ច នៃដែនជម្រកសត្វព្រៃស្រែពក បានធ្វើការបង្ក្រាបជាក់ស្តែង និងឃាត់ខ្លួនជនជាប់ចោទនៅនឹងកន្លែង។

២. តាមចម្លើយរបស់ជនជាប់ចោទ ដែលបានបញ្ជាក់ថា នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ ខ្លួនបានយកដើមចេក ចំនួន ៥០ដើម ទៅដាំនៅលើដីចំណុចអន្ទ្រាច់ ស្ថិតនៅភូមិអរបួន ឃុំអរបួនលើ ស្រុកកោះញែក ខេត្តមណ្ឌលគិរី ក្នុងគោលបំណងឱ្យគណៈកម្មការថ្នាក់ជាតិបានឃើញដំណាំ និងអាចឈ្លៀលដីនោះឱ្យខ្លួន។ នៅពេលដាំដើមចេក ខ្លួនបានដឹងថាដីនោះជាដីហាមឃាត់របស់បរិស្ថាន ដោយមានបង្គោលហាមឃាត់ផងដែរ ហើយដីនេះ ប្រពន្ធខ្លួនធ្លាប់ធ្វើកិច្ចសន្យាម្តងរួចមកហើយ។ ផ្អែកតាមចម្លើយនេះ បង្ហាញឱ្យឃើញថា ជនជាប់ចោទមានចេតនាទុច្ចរិតក្នុងការ កាប់រានដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ ហើយអំពើនេះត្រូវបានច្បាប់បញ្ញត្តិជាបទល្មើសព្រហ្មទណ្ឌតាមមាត្រា៦២ ចំណុច១ និងមាត្រា៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

៣. អំពើរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិរបស់រដ្ឋ និងប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយល្អរបស់សង្គម។

៤. ជនជាប់ចោទ ជានីតិជន មាននីតិសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណណាមួយ ដែលនាំឱ្យមានមន្ទិលសង្ស័យថាជននេះមានបញ្ហាវិកលសស្មារតីក្នុងពេលប្រព្រឹត្តល្មើសឡើយ។ ជនជាប់ចោទជាសមត្ថជន ដែលមានការពិចារណា ព្រមទាំងយល់ដឹងអំពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតនៅក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។

៥. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ តម្កល់ការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៥៤២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ ទុកជាបានការដដែល។ ទន្ទឹមនឹងនោះ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ



Scanned with CamScanner

បានធ្វើសេចក្តីសន្និដ្ឋានស្នើសុំឲ្យតុលាការផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន ដោយហេតុថាកូនក្តីខ្លួនរៀនសូត្របានតិចតួច មិនសូវយល់ដឹង ហើយមានជីវភាពក្រីក្រទៀតផង។ តុលាការយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ មានភាពត្រឹមត្រូវ ដែលអាចឲ្យតុលាការពិចារណាតាមច្បាប់។

៦. មានធាតុផ្សំបទល្មើស និងមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សាម៉ែន** ភេទប្រុស កើតថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៨៧ ពីបទ **កាប់គាស់រុករានដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅចំណុចអូរអន្ទ្រាច់ ស្ថិតនៅភូមិអរប្លួន ឃុំអរប្លួនលើ ស្រុកកោះញែក ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌចែងឲ្យផ្តន្ទាទោសតាមមាត្រា៦២ ចំណុច១ និងមាត្រា៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

៧. តាមឯកសារភស្តុតាងក្នុងសំណុំរឿង បញ្ជាក់បានថា ជនជាប់ចោទពុំធ្លាប់មានការផ្តន្ទាទោសជាស្ថាពរឲ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥(ប្រាំ)ឆ្នាំ មុនអំពើល្មើសឡើយ។ ម្យ៉ាងទៀតជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ហើយជនជាប់ចោទមានរៀនសូត្របានតិចតួច និងមានជីវភាពក្រីក្រ គប្បីតុលាការពិចារណាអំពីការព្យួរទោសមួយផ្នែកតាមបញ្ញត្តិមាត្រា១០៦ មាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

**សេចក្តីសម្រេច**

១. ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted]**សាម៉ែន** ភេទប្រុស កើតថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៨៧ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥(ប្រាំ)ឆ្នាំ តែអនុវត្តទោសក្នុងពន្ធនាគាររយៈពេល ០១(មួយ)ឆ្នាំ និង ០៦(ប្រាំមួយ)ខែ ទោសដែលនៅសល់ត្រូវព្យួរ និងពិន័យជាប្រាក់ ១៥.០០០.០០០ (ដប់ប្រាំលាន)រៀល។

ពីបទ៖ **កាប់គាស់រុករានដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅចំណុចអូរអន្ទ្រាច់ ស្ថិតនៅភូមិអរប្លួន ឃុំអរប្លួនលើ ស្រុកកោះញែក ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌចែងឲ្យ ផ្តន្ទាទោសតាមមាត្រា៦២ ចំណុច១ និងមាត្រា៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

សាលក្រមនេះ ប្រកាសជាសាធារណៈនៅថ្ងៃពុធ ១១រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ។

ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ |

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១១រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
មណ្ឌលគិរី,ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០២១
**ក្រឡាបញ្ជី**

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

[redacted]